# ផែនការនៃការកែលម្អភាពសមធម៌ផ្នែកសុខភាពនៅតាមសហគមន៍ សម្រាប់ខោនធី Los Angeles

ពីឆ្នាំ 2024 ដល់ឆ្នាំ 2029



បានកែសម្រួលចុងក្រោយបង្អស់នៅ៖ 10/03/2024 (Cambodian)

# តើផែនការនៃការកែលម្អភាពសមធម៌ផ្នែកសុខភាពនៅតាមសហគមន៍ (Community Health Equity Improvement Plan/CHEIP) គឺជាអ្វី?

នេះគឺជាផែនការរួមគ្នាមួយរវាងនាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (Los Angeles County Department of Public Health/Public Health) ដៃគូការងារនានា និងអ្នកចូលរួមចំណែកទាំងឡាយ ដើម្បីធ្វើឱ្យភាពសមធម៌ផ្នែកសុខភាពបានជឿនលឿន ហើយនិងជួយឱ្យសហគមន៍នានាបានចម្រើនឡើងប្រកបដោយសុខភាពល្អ និងមានភាពជោគជ័យ។

ក្នុងអំឡុងពេលការបង្កើតផែនការនេះឡើង Public Health បានសហការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូ និងអ្នកចូលរួមចំណែកទាំងឡាយនៅក្នុងសហគមន៍ ដើម្បីពិនិត្យមើលទិន្នន័យថ្មីបំផុតដែលអាចរកបាន និងកំណត់វិធីសាស្ត្រផ្សេងៗដែលនឹងជះឥទ្ធិពលជារួមទៅលើបញ្ហាផ្នែកសុខភាពសាធារណជនសំខាន់ៗមួយចំនួននៅក្នុងខោនធី Los Angeles។

CHEIP នេះឆ្លុះបញ្ចាំងអំពីបញ្ហាសុខភាពរបស់ប្រជាជនដែលនៅតែមានអទិភាពដ៏ខ្ពស់ និងពង្រឹងដល់ចំណុចសំខាន់នៃការធ្វើជាដៃគូ ក៏ដូចជាការធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងទាំងឡាយស្របទៅតាមគ្នា ដើម្បីទទួលបានភាពសមធម៌ ហើយនិងគាំទ្រដល់សុខភាពជារួម ផងដែរ។

## ចំណុចត្រូវផ្តោតទៅលើនានា

- ការអាចនឹងស្លាប់របស់ទារក និងម្តាយជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក
- ការឆ្លងមេរោគតាមផ្លូវភេទ និងរោគស្វាយពីកំណើត
- ភាពយុត្តិធម៌ផ្នែកបរិស្ថាន
- ការទប់ស្កាត់អំពើហិង្សា

# ភាពសមធម៌ជាមូលដ្ឋានមួយ

## ភាពសមធម៌ផ្នែកសុខភាពគឺសម្រេចបាននៅពេលដែលមនុស្សគ្រប់រូបមានឱកាសមួយដែលស្មើភាព និងយុត្តិធម៌ក្នុងការទទួលបានសុខភាព និងសុខុមាលភាពរបស់ពួកគេក្នុងកម្រិតប្រសើរបំផុត។

CHEIP បង្កើតបន្ថែមទៅលើលំនាំផ្នែកភាពសមធម៌ (Equity Framework) ដែលបានបង្កើតឡើង ដើម្បីនាំផ្លូវគម្រោង ឬក៏នាំផ្លូវការធ្វើឱ្យបានប្រសើរឡើងចំពោះកម្មវិធី ឬដំណើរការផ្សេងៗ។ វិធីសាស្ត្រទាំងឡាយគឺបានរៀបចំដោយយោងទៅតាមចំណុចអាទិភាពផ្នែកភាពសមធម៌ (Equity Priorities) ទាំងឡាយខាងក្រោមនេះ៖

ធ្វើឱ្យអាចទទួលបានទិន្នន័យនៃភាពសមធម៌ផ្នែកសុខភាពដែលមានប្រយោជន៍ និងមានការគិតគូរដល់មនុស្សគ្រប់រូប។

គាំទ្រដល់ការផ្លាស់ប្តូរគោលការណ៍ និងប្រព័ន្ធគ្រប់គ្រងផ្សេងៗសម្រាប់ឱ្យមានការចែករំលែកឱកាស និងធនធានផ្សេងៗក្នុងលក្ខណៈមួយដែលប្រកបទៅដោយភាពសមធម៌។

កសាងភាពជាដៃគូផ្សេងៗដែលចែករំលែកអំណាចយ៉ាងពិតប្រាកដ និងគោរពដល់ការមានសិទ្ធិម្ចាស់ការរបស់សហគមន៍។

ជួយពង្រឹងដល់ភាពត្រៀមខ្លួនជាស្រេច និងលទ្ធភាពផ្នែកការចាត់តាំងក្នុងការទទួលយកទម្លាប់មួយដែលយុត្តិធម៌មកប្រើប្រាស់ ហើយនិងធ្វើឱ្យភាពសមធម៌ផ្នែកសុខភាពបានឿនលឿន។

# ចូលរួមចំណែក

CHEIP ផ្ដល់ចំណុចចាប់ផ្ដើមជារួមសម្រាប់ចំណុចដែលត្រូវផ្ដោតទៅលើជាក់លាក់ផ្សេងៗ និងទទួលស្គាល់ថាកិច្ចខំប្រឹងប្រែងរបស់អង្គការ ទីភ្នាក់ងារ អ្នកចូលរួមចំណែក និងសមាជិកផ្សេងទៀតនៅក្នុងសហគមន៍ក៏ធ្វើឱ្យភាពសមធម៌បានជឿនលឿន ហើយនិងធ្វើឱ្យលទ្ធផលផ្នែកសុខភាពបានប្រសើរឡើងផងដែរ។

ផ្នែកនីមួយៗនៅក្នុង CHEIP នេះផ្ដល់ជូន "សកម្មភាពបែបសហការ (Collaborative Actions)" បន្ថែមទៀតដែលអាចអនុវត្តទៅបាន ដើម្បីគាំទ្រ ឬបង្គ្រប់ដល់កិច្ចការទាំងឡាយដែលបានកំណត់នៅក្នុង CHEIP នេះ។

ខណៈដែល Public Health និងដៃគូទាំងឡាយដាក់អនុវត្ត CHEIP នេះ យើងខ្ញុំមានគម្រោងក្នុងការបន្ថែមចំណុច និងព័ត៌មានថ្មីៗទៅក្នុងផែនការនេះ ដោយរួមមានឱកាសបន្ថែមទៀតក្នុងការធ្វើឱ្យឥទ្ធិពលជារួមទៅលើចំណុចអទិភាពនានាផ្នែកសុខភាពដែលមានគោលដៅច្បាស់លាស់បានជឿនលឿន ផងដែរ។

**សម្រាប់ព័ត៌មានថ្មីៗ សូមចូលទៅកាន់គេហទំព័រ៖**

http://publichealth.lacounty.gov/pie/planning/chip.htm

## ចំណុចត្រូវផ្តោតទៅលើទី 1៖ ការអាចនឹងស្លាប់របស់ទារក និងម្តាយជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក

### សេចក្តីថ្លែងការណ៍អំពីលទ្ធផល៖

ទារក និងម្តាយ/អ្នកផ្តល់កំណើតជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិកទាំងអស់នៅក្នុងខោនធី Los Angeles រីករាយនឹងផ្តល់កំណើតប្រកបដោយសុខភាពល្អ និងភាពសប្បាយ ហើយចម្រើនលូតលាស់យ៉ាងយូរលើសពីខួបកំណើតទីមួយរបស់ទារក ផងដែរ។

### គោលដៅដែលអាចស្ទង់បាន៖

ក្នុងរយៈពេលប្រាំឆ្នាំ ត្រូវកាត់បន្ថយចន្លោះអត្រានៃការស្លាប់របស់ទារក (Infant Mortality Rates/IMR) រវាងទារកជនជាតិស្បែកស និងទារកជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិកឱ្យបានចំនួន 50% តាមរយៈការកាត់បន្ថយ IMR របស់ជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក។



# វិធីសាស្ត្រផ្សេងៗ

## ទិន្នន័យដែលមានប្រយោជន៍ និងមានការគិតគូរដល់មនុស្សគ្រប់រូប

**វិធីសាស្ត្រទី 1៖** គិតត្រឹមខែមិថុនា ឆ្នាំ 2025 ត្រូវចាប់ផ្តើមដំណើរការ និងរក្សាឱ្យមានរបាយការណ៍ដែលមានក្រាហ្វិកទិន្នន័យដែលសាធារណជនអាចប្រើប្រាស់បាននៃការអាចនឹងស្លាប់របស់ម្តាយ និងទារក ហើយនិងទិន្នន័យជាប់ពាក់ព័ន្ធ ដោយបំបែកទៅតាមជាតិសាសន៍/ជនជាតិ។



## ការផ្លាស់ប្តូរគោលការណ៍ និងប្រព័ន្ធគ្រប់គ្រងផ្សេងៗ

**វិធីសាស្ត្រទី 2៖** គិតត្រឹមខែមិថុនា ឆ្នាំ 2026 ត្រូវវាយតម្លៃទៅលើការដាក់អនុវត្តន៍គំនិតផ្តួចផ្តើមទាក់ទងទៅនឹងការមានលំនឹងផ្នែកប្រាក់កាសមួយ ដូចជាកម្មវិធីប្រាក់ចំណូលដែលមានការធានា (Guaranteed Income) ដែលបម្រើការជូនដល់អ្នកមានផ្ទៃពោះយ៉ាងហោចណាស់ចំនួន 400 នាក់ដែលទទួលរងឥទ្ធិពលដោយភាពខុសគ្នាផ្សេងៗផ្នែកសុខភាពក្នុងពេលជិតសម្រាល ឬពេលទើបសម្រាលរួច។

**វិធីសាស្ត្រទី 3៖** គិតត្រឹមខែមិថុនា ឆ្នាំ 2027 ត្រូវបន្ថែមកម្មវិធីអ្នកផ្តល់ជំនួយ (Doula Program) របស់គំនិតផ្តួចផ្តើមទាក់ទងទៅនឹងការអាចនឹងស្លាប់របស់ទារក និងម្តាយជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក (African American Infant and Maternal Mortality/AAIMM) ទៅក្នុងប្រព័ន្ធគ្រប់គ្រងផ្នែកសុខភាពដែលទាក់ទងឱ្យបានយ៉ាងហោចណាស់ចំនួនបីកន្លែង ដើម្បីកែលម្អដល់ការទទួលបានការថែទាំដល់ម្តាយក្នុងលក្ខណៈមួយដែលបញ្ជាក់បន្ថែមទៅលើផ្នែកវប្បធម៌ និងមានការគាំទ្រ។



## ការកសាងភាពជាដៃគូផ្សេងៗ

**វិធីសាស្ត្រទី 4៖** គិតត្រឹមខែមិថុនា ឆ្នាំ 2027 ត្រូវផ្ដល់ទឹកប្រាក់ដល់អង្គការនៅក្នុងសហគមន៍ឱ្យបានយ៉ាងហោចណាស់ចំនួន 10 កន្លែង ដើម្បីផ្ដល់ជូននូវសេវាកម្មផ្នែកការកាត់បន្ថយភាពតានតឹង និងជំនួយដល់ក្រុមគ្រួសារជនជាតិស្បែកខ្មៅដែលមានផ្ទៃពោះ ឬកំពុងធ្វើជាឪពុកម្ដាយតាមរយៈមូលនិធិជំនួយពីសហគមន៍ (Village Fund) សម្រាប់គំនិតផ្តួចផ្តើម AAIMM។

## ភាពត្រៀមខ្លួនរួចជាស្រេច និងលទ្ធភាពផ្នែកការចាត់តាំង

**វិធីសាស្ត្រទី 5៖** គិតត្រឹមខែធ្នូ ឆ្នាំ 2025 ត្រូវជួយពង្រឹងដល់សមត្ថភាពរបស់ក្រុមចុះធ្វើសកម្មភាពនៅក្នុងសហគមន៍ (Community Action Teams) ក្នុងការកំណត់តម្រូវការផ្សេងៗក្នុងតំបន់ ហើយនិងបង្កើត និងដាក់អនុវត្តវិធីសាស្ត្រថ្មីឱ្យបានយ៉ាងហោចណាស់ចំនួនមួយចំណុច ជាការឆ្លើយតបទៅនឹងការវាយតម្លៃតម្រូវការផ្សេងៗនៅក្នុងតំបន់ ដែលបានដាក់អនុវត្ត ដើម្បីដោះស្រាយចំពោះបញ្ហាកម្រិតខុសគ្នាដោយមិនអាចប្រៀបធៀបបាននៃការអាចនឹងស្លាប់របស់ទារក និងម្ដាយជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក។

**វិធីសាស្ត្រទី 6៖** គិតត្រឹមខែមិថុនា ឆ្នាំ 2026 ត្រូវបញ្ចប់ផែនការតាមវិធីសាស្ត្រត្រឹមត្រូវមួយសម្រាប់រយៈពេលចាប់ពីបី ទៅប្រាំឆ្នាំតាមរយៈការសម្រេចចិត្តជារួមនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ (Steering Committee) របស់គំនិតផ្តួចផ្តើម AAIMM។

# សកម្មភាពបែបសហការ

### 1. គាំទ្រមតិផ្នែកការផ្លាស់ប្តូរគោលការណ៍ និងប្រព័ន្ធគ្រប់គ្រងផ្សេងៗ

គាំទ្រដល់គោលការណ៍ និងគំរូអនុវត្តន៍ផ្សេងៗដែលផ្តល់អទិភាពដល់ភាពសមធម៌ផ្នែកសុខភាពរបស់ម្តាយនិងទារក ដោះស្រាយចំពោះបញ្ហាការរើសអើងជាតិសាសន៍និងការរើងអើងទូទៅនៅក្នុងប្រព័ន្ធគ្រប់គ្រងសង្គម ហើយនិងកែលម្អដល់ការទទួលបាននិងការប្រើប្រាស់ប្រព័ន្ធថែទាំសុខភាពស្ថានភាពផ្ទះសម្បែងដែលមានលំនឹង ព្រមទាំងជំនួយក្នុងលក្ខណៈផ្សេងទៀតសម្រាប់បុគ្គល និងក្រុមគ្រួសារជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក។

### 2. ចូលរួមចំណែកដល់ការស្រាវជ្រាវ និងទិន្នន័យដែលមានការគិតគូរដល់មនុស្សគ្រប់រូប

ដាក់បន្ថែមចំណុចផ្សេងៗទៅក្នុងសំណុំទិន្នន័យចំពោះការអាចនឹងស្លាប់របស់ម្តាយ និងទារក ហើយនិងទិន្នន័យដែលជាប់ពាក់ព័ន្ធ ដោយបំបែកទៅតាមជាតិសាសន៍ និងជនជាតិ ដើម្បីយល់ដឹងឱ្យបានកាន់តែល្អចំពោះមូលហេតុដើមទាំងឡាយនៃភាពខុសគ្នាទាក់ទងទៅនឹងជាតិសាសន៍ចំពោះលទ្ធផលនានាផ្នែកសុខភាពរបស់ម្តាយ និងទារក ក៏ដូចជាដើម្បីកំណត់ក្នុងលក្ខណៈកាន់តែល្អចំពោះរបៀបធ្វើអន្តរាគមន៍ដែលមានប្រសិទ្ធិភាពក្នុងការដោះស្រាយចំពោះបញ្ហាទាំងនេះទាំងនៅខាងក្នុង និងនៅខាងក្រៅស្ថាប័នរបស់អ្នកផ្ទាល់។

### 3. ចូលរួមធ្វើសកម្មភាពក្នុងចំណុចអទិភាពទាំងឡាយដែលមានការជំរុញដោយសហគមន៍

ចូលរួមចំណែកជាមួយនឹងសហគមន៍នានា និងសមាជិកក្នុងសហគមន៍ក្នុងការបង្កើត និងការដាក់អនុវត្តន៍វិធីសាស្រ្ត និងគំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីជួយ និងសម្តែងសេចក្តីត្រេកអរជូនដល់ក្រុមគ្រួសារជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិកទាំងឡាយដែលមានផ្ទៃពោះ ឬកំពុងធ្វើជាឪពុកម្តាយ។

### 4. គាំទ្រដល់កម្មវិធីផ្សេងៗនៅតាមសហគមន៍ និងសេវាកម្មផ្សេងៗផ្នែកជំនួយក្នុងសង្គម

គាំទ្រ ផ្តល់ទឹកប្រាក់ និង/ឬជួយដល់កម្មវិធីផ្សេងៗដែលផ្តល់ការអប់រំ (ឧ. ថ្នាក់អប់រំជាក្រុមសម្រាប់ពេលមានគភ៌ ការអាចគ្រប់គ្រងផ្នែកប្រាក់កាសបាន វិធីគ្រប់គ្រងភាពតានតឹង ជំនួយផ្នែកបំបៅកូនដោយទឹកដោះ) ការប្រឹក្សា (សុខភាពផ្លូវចិត្ត ការចិញ្ចឹមរាងកាយ) ធនធានផ្សេងៗ ជំនួយក្នុងការទទួលបានការថែទាំសុខភាព ឬក៏សេវាកម្មផ្សេងៗផ្នែកជំនួយក្នុងសង្គម (ឧ. ការចូលរួមធ្វើកិច្ចការនៅពេលធ្វើជាឪពុក) សម្រាប់ស្ត្រីជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិកមានផ្ទៃពោះ និងក្រុមគ្រួសារកំពុងធ្វើជាឪពុកម្តាយ។

### 5. ធ្វើឱ្យការកែប្រែផ្នែកការចាត់តាំងបានជឿនលឿន

បង្កើនការអប់រំ ការយល់ដឹង និងការសង្កេតឃើញនៃការអាចនឹងស្លាប់របស់ទារក និងម្តាយជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិកថាជាបញ្ហាផ្នែកសុខភាពសាធារណជន។ លុបបំបាត់ការយល់ឃើញផ្សេងៗដែលស្តីបន្ទោសដល់ស្ត្រីជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក។ ផ្ទុយទៅវិញ ចូរកំណត់ការរើសអើងជាតិសាសន៍ ហើយធ្វើកិច្ចការផ្សេងៗសម្រាប់ឱ្យមានការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រង។ គាំទ្រដល់អង្គការ និងទីភ្នាក់ងារទាំងឡាយដែលមានការសំដៅទៅលើសេវាកម្មក្នុងការបង្កើនភាពត្រៀមខ្លួនជាស្រេច និងលទ្ធភាពផ្នែកការចាត់តាំង ដើម្បីយល់ដឹងឱ្យបានកាន់តែល្អ និងស្របតាមតម្រូវការនានាដែលមានលក្ខណៈពិសេសរបស់ពលរដ្ឋជនជាតិស្បែកខ្មៅ/ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិកទាំងឡាយ។

# ចំណុចត្រូវផ្តោតទៅលើទី 2៖ ការឆ្លងមេរោគតាមផ្លូវភេទ (Sexually Transmitted Infections) និងរោគស្វាយពីកំណើត (Congenital Syphilis)



## សេចក្តីថ្លែងការណ៍អំពីលទ្ធផល៖

មនុស្សគ្រប់រូបនៅក្នុងខោនធី Los Angeles ដោយរួមមានទាំងមនុស្សជំនាន់ក្រោយផងដែរនោះ គឺមានការគាំពារពីការឆ្លងមេរោគតាមផ្លូវភេទ និងរោគស្វាយពីកំណើត។

## គោលដៅដែលអាចស្ទង់បាន៖

អត្រានៃរោគស្វាយដំណាក់កាលដំបូង (primary syphilis) និងរោគស្វាយដំណាក់កាលបែក (secondary syphilis) ក្នុងចំណោមបុរសដែលរួមភេទជាមួយនឹងបុរស (MSM) ជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក និងជនជាតិអាមេរិកឡាទីននឹងធ្លាក់ចុះក្នុងចំនួន 20% ក្នុងរយៈពេលប្រាំឆ្នាំ។

# វិធីសាស្ត្រផ្សេងៗ

## ទិន្នន័យដែលមានប្រយោជន៍ និងមានការគិតគូរដល់មនុស្សគ្រប់រូប

**វិធីសាស្ត្រទី 1៖** គិតត្រឹមខែធ្នូ ឆ្នាំ 2024 និងបន្តទៅមុខទៀត ត្រូវចែកចាយទិន្នន័យអំពីមេរោគ HIV និង STI ដែលមានព័ត៌មានថ្មីៗ ហើយងាយស្រួលនឹងយល់បាន ដោយមានការធានាថាអាចយកមកប្រើប្រាស់ និងអាចផ្លាស់ប្តូរព័ត៌មានគ្នាបាន ដើម្បីផ្តល់ជំនឿចិត្ត ព្រមទាំងជូនដំណឹងដល់សហគមន៍។



## ការផ្លាស់ប្តូរគោលការណ៍ និងប្រព័ន្ធគ្រប់គ្រងផ្សេងៗ

**វិធីសាស្ត្រទី 2៖** គិតត្រឹមខែធ្នូ ឆ្នាំ 2027 ត្រូវកែលម្អដល់ការគោរពតាមច្បាប់នៃរដ្ឋ California និងសេចក្តីណែនាំរបស់ខោនធី LA ដែលបញ្ជាឱ្យមានការត្រួតពិនិត្យរករោគស្វាយសម្រាប់អ្នកផ្ទៃពោះទាំងអស់ ក្នុងអំឡុងពេលការពិនិត្យលើកដំបូងក្នុងពេលមានគភ៌របស់ពួកគេ ហើយមានការណែនាំឱ្យត្រួតពិនិត្យបន្ថែមទៀតក្នុងអំឡុងពេលត្រីមាសទីបី (ចាប់ពី 28 ទៅ 32 សប្តាហ៍) និងនៅពេលសម្រាល។

**វិធីសាស្ត្រទី 3៖** គិតត្រឹមខែធ្នូ ឆ្នាំ 2025 ត្រូវបង្កើនអត្រានៃការត្រួតពិនិត្យ និងការធ្វើតេស្តរក STI ក្នុងចំណោមប្រជាជនដែលប្រឈមនឹងហានិភ័យកាន់តែខ្ពស់ចំពោះ STI នានា តាមរយៈការជួយពង្រឹងដល់ការប្រុងប្រយ័ត្ន និងការយល់ដឹងរបស់សហគមន៍ចំពោះ STI នានា។

## ការកសាងភាពជាដៃគូផ្សេងៗ

**វិធីសាស្ត្រទី 4៖** គិតត្រឹមខែមករា ឆ្នាំ 2025 ត្រូវបង្កើតឱ្យមានក្រុមប្រឹក្សាដែលមានភាពជាដៃគូ សម្រាប់ទទួចសុំដំបូន្មាន ឬមតិប្រតិកម្មពីសហគមន៍ទៅតាមទម្លាប់ ដើម្បីកំណត់កិច្ចការ ឬសកម្មភាពទាំងឡាយដែលនឹងកែលម្អដល់កិច្ចខំប្រឹងប្រែងផ្នែកការទប់ស្កាត់ ហើយនិងការគ្រប់គ្រង STI។

## ភាពត្រៀមខ្លួនជាស្រេច និងលទ្ធភាពផ្នែកការចាត់តាំង

**វិធីសាស្ត្រទី 5៖** គិតត្រឹមខែធ្នូ ឆ្នាំ 2025 ត្រូវបង្កើតឱ្យមានកម្មវិធីដែលមានលក្ខណៈពេញលេញមួយ ដើម្បីផ្តល់វគ្គបង្ហាត់ដែលមានគោលដៅច្បាស់លាស់ជូនដល់អ្នកស៊ើបអង្កេតផ្នែកសុខភាពសាធារណជន (public health investigators/PHIs) អ្នកឯកទេសផ្នែកការទប់ស្កាត់ជំងឺដែលជាផ្នែកមួយរបស់សហគមន៍ (community-embedded disease prevention specialists/CEDIS) ហើយនិងបុគ្គលិកជួរមុខនៅតាមគ្លីនិក ឱ្យបានទៀងទាត់។





# សកម្មភាពបែបសហការ

### 1. បង្កើនការពិនិត្យរករោគស្វាយ

ដាក់អនុវត្តវិធីពិនិត្យរក និងការព្យាបាលសម្រាប់រោគស្វាយដែលអាចអនុវត្តចំពោះស្ថានភាពជាច្រើនបាន សម្រាប់ប្រជាជនដែលប្រឈមនឹងហានិភ័យ ដោយរួមមានស្ត្រីក្នុងវ័យអាចបន្តពូជបាន និងស្ត្រីមានផ្ទៃពោះ ផងដែរ។

### 2. ធ្វើឱ្យការប្រុងប្រយ័ត្នចំពោះ STI បានខ្ពស់ជាងមុន

បង្កើនការអប់រំ និងការប្រុងប្រយ័ត្នចំពោះ STI នានា ដោយរួមមានរោគស្វាយផងដែរនោះ ក្នុងចំណោមអ្នកដែលប្រឈមនឹងហានិភ័យខ្ពស់បំផុត។ រួមបញ្ចូលយុទ្ធនាការផ្នែកការកាត់បន្ថយគំនិតអវិជ្ជមាន ដើម្បីប្រយុទ្ធប្រឆាំងនឹងគំនិតអវិជ្ជមានផ្សេងៗដែលជាប់ពាក់ព័ន្ធទៅនឹង STI នានា ដែលគំនិតអវិជ្ជមានទាំងនេះអាចក្លាយទៅជាឧបសគ្គដល់ការធ្វើតេស្ត ការព្យាបាល និងការបង្ហាញព័ត៌មានចេញមក។ ដំណឹងផ្សេងៗគួរតែរួមមានចំណុចសំខាន់នៃការដាក់បញ្ចូលការធ្វើតេស្តទៅជាផ្នែកមួយនៃការថែទាំសុខភាពតាមទម្លាប់។

### 3. ប្រើប្រាស់លំនាំនៃការថែទាំដែលមានកម្រិតកាន់តែប្រសើរឡើង (Enhanced Care Models) សម្រាប់ស្ត្រីទាំងឡាយដែលកំពុងជួបប្រទះនឹងភាពងាយស្រួលនឹងរងគ្រោះក្នុងកម្រិតខ្ពស់

ប្រើប្រាស់លំនាំដែលមានកម្រិតកាន់តែប្រសើរឡើង ដើម្បីស្របទៅតាមតម្រូវការផ្សេងៗរបស់ស្ត្រីមានឧបសគ្គផ្នែកបញ្ហាសុខភាពខុសៗគ្នាដែលកើតមានក្នុងពេលតែមួយ ដូចជាបញ្ហាប្រើប្រាស់គ្រឿងញៀន និងភាពមិនមានផ្ទះសម្បែង ជាការធ្វើអន្តរាគមន៍ក្នុងលក្ខណៈសំខាន់យ៉ាងខ្លាំងមួយចំពោះរោគស្វាយ។

### 4. ជួយពង្រឹងដល់ភាពត្រៀមខ្លួនជាស្រេចផ្នែកការចាត់តាំង ដើម្បីផ្តល់ការថែទាំក្នុងលក្ខណៈមួយដែលមានការយល់ដឹងផ្នែកវប្បធម៌

បង្កើនលទ្ធភាពនៃកម្លាំងការងារ ដើម្បីផ្តល់ជូននូវវិធីទប់ស្កាត់ STI ក្នុងលក្ខណៈមួយដែលមានការយល់ដឹងផ្នែកវប្បធម៌ និងមានភាពត្រឹមត្រូវខាងភាសា។ ដោះស្រាយចំពោះបញ្ហាឧបសគ្គផ្នែកភាសា បទដ្ឋានផ្នែកវប្បធម៌ ព្រមទាំងកត្តាផ្សេងៗផ្នែកសង្គម ហើយនិងប្រាក់កាសដែលអាចនឹងជះឥទ្ធិពលទៅលើការអាចទទួលបានការថែទាំ និងលទ្ធផលផ្នែកសុខភាពផ្សេងៗផងដែរ។

### 5. ប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃមេរោគ HIV និង STI នានា

នៅតាមអង្គការដែលផ្អែកទៅលើសាសនា ទីក្រុងនានា ហើយនិងអង្គការ និងអាជីវកម្មនៅក្នុងតំបន់ ដាក់អនុវត្តវគ្គអប់រំ ឬយុទ្ធនាការផ្នែកសុខភាពផ្លូវភេទ ក្លាយទៅជាទីតាំងចែកចាយស្រោមអនាម័យ ហើយនិងធ្វើកិច្ចការយ៉ាងសកម្មក្នុងការលុបបំបាត់គំនិតអវិជ្ជមាន និងការរើសអើងដែលបុគ្គល និងសហគមន៍ប្រឈមនឹងហានិភ័យកាន់តែខ្ពស់ចំពោះមេរោគ HIV និង STI នានា ត្រូវជួបប្រទះ។ ទីភ្នាក់ងារនៅតាមសហគមន៍ក្នុងតំបន់ និងអ្នកផ្តល់សេវាកម្មទាំងឡាយអាចផ្តល់ ឬជួយសម្រួលដល់ការទទួលបានកម្មវិធីផ្នែកការទប់ស្កាត់ ការធ្វើតេស្ត ព្រមទាំងសេវាកម្មផ្នែកការព្យាបាល ហើយនិងគាំទ្រដល់កម្មវិធីសេវាកម្មសម្រាប់ដៃគូ (ឧ. ការស្នើសុំព័ត៌មានពីដៃគូ ឬការផ្តល់ដំណឹងជូនដល់ដៃគូ) សម្រាប់ប្រជាជនដែលប្រឈមនឹងហានិភ័យកាន់តែខ្ពស់ចំពោះមេរោគ HIV និង STI នានា។

## សេចក្តីថ្លែងការណ៍អំពីលទ្ធផល៖

អ្នកដែលកំពុងរស់នៅក្នុងសហគមន៍ដែលមានបន្ទុកដោយសារការបំពុលបរិស្ថានក្នុងកម្រិតខ្ពស់បំផុតនៅក្នុងខោនធី Los Angeles រីករាយនឹងមានជីវិតប្រកបដោយសុខភាពល្អ ហើយមានសុវត្ថិភាពពីការប៉ះពាល់ទៅនឹងជាតិពុល និងមានសុវត្ថិភាពពីឥទ្ធិពលក្នុងលក្ខណៈអវិជ្ជមាននៃបញ្ហាផ្លាស់ប្តូរអាកាសធាតុ។

## គោលដៅដែលអាចស្ទង់បាន៖

ក្នុងរយៈពេលប្រាំឆ្នាំ ត្រូវស្វែងរក និងដោះស្រាយបញ្ហាប្រភពផ្សេងៗនៃការប៉ះពាល់ទៅនឹងជាតិសំណចំពោះកុមារទាំងឡាយដែលមានកម្រិតជាតិសំណក្នុងឈាមចំនួនចាប់ពី 3.5 µg/dL ឡើងទៅ ហើយដែលរស់នៅក្នុងសហគមន៍ដែលមានការបំពុលបរិស្ថានច្រើនបំផុតនៅក្នុងខោនធី Los Angeles ឱ្យបានយ៉ាងហោចណាស់ចំនួន 25%។

# ចំណុចត្រូវផ្តោតទៅលើទី 3៖ ភាពយុត្តិធម៌ផ្នែកបរិស្ថាន



# វិធីសាស្ត្រផ្សេងៗ

## ទិន្នន័យដែលមានប្រយោជន៍ និងមានការគិតគូរដល់មនុស្សគ្រប់រូប

**វិធីសាស្ត្រទី 1៖** គិតត្រឹមខែធ្នូ ឆ្នាំ 2025 ត្រូវផ្សព្វផ្សាយទិន្នន័យនៅលើវេទិកាដែលសាធារណជនអាចប្រើប្រាស់បាន ហើយដែលបង្ហាញអំពីព័ត៌មានផ្នែកបរិស្ថាន ផ្នែកអាកាសធាតុ និងផ្នែកបញ្ហាសុខភាពទាំងឡាយដែលមានការទាក់ទង ដោយមានព័ត៌មានពីដំបូន្មានរបស់អ្នកចូលរួមចំណែកនៃការរៀបចំផែនការតាមវិធីសាស្ត្រត្រឹមត្រូវ។

**វិធីសាស្ត្រទី 2៖** គិតត្រឹមខែធ្នូ ឆ្នាំ 2025 និងជារៀងរាល់ឆ្នាំបន្តពីនេះ ត្រូវធានាថាគេហទំព័រកម្មវិធីរបស់ការិយាល័យនៃភាពយុត្តិធម៌ផ្នែកបរិស្ថាន និងសុខភាពទាក់ទងទៅនឹងអាកាសធាតុ (Office of Environmental Justice and Climate Health/OEJCH) ផ្តល់ព័ត៌មានទាន់ហេតុការណ៍ និងមានការពាក់ព័ន្ធ ជូនដល់សាធារណជន ដោយផ្អែកទៅលើដំបូន្មានទទួលបានពីការចូលរួមរបស់អ្នកចូលរួមចំណែកក្នុងការរៀបចំផែនការតាមវិធីសាស្ត្រត្រឹមត្រូវ។

## ការផ្លាស់ប្តូរគោលការណ៍ និងប្រព័ន្ធគ្រប់គ្រងផ្សេងៗ

**វិធីសាស្ត្រទី 3៖** គិតត្រឹមខែធ្នូ ឆ្នាំ 2025 ត្រូវបង្កើតកាលវិភាគគោលការណ៍ជាលក្ខណៈដំបូងអំពីភាពយុត្តិធម៌ផ្នែកបរិស្ថានដែលមានអទិភាព និងបញ្ហាសុខភាពទាក់ទងទៅនឹងអាកាសធាតុដែលកំណត់គោលការណ៍នានាឱ្យបានយ៉ាងហោចណាស់ចំនួន 3 ចំណុច ដើម្បីចាត់វិធានការណ៍ក្នុងការអនុវត្តន៍។





## ភាពត្រៀមខ្លួនជាស្រេច និងលទ្ធភាពផ្នែកការចាត់តាំង

**វិធីសាស្ត្រទី 7៖** គិតត្រឹមខែមករា ឆ្នាំ 2027 ត្រូវដាក់អនុវត្តផែនការតាមវិធីសាស្ត្រត្រឹមត្រូវដែលបានបង្កើតឡើងក្នុងលក្ខណៈសហការជាមួយនឹង OEJCH ដើម្បីកាត់បន្ថយភាពខុសគ្នាផ្នែកសុខភាពដោយសារតែការប៉ះពាល់ទៅនឹងកត្តាបង្កបញ្ហានៅក្នុងបរិស្ថាននៅតាមសហគមន៍ទាំងឡាយដែលមានបន្ទុកយ៉ាងលើសលប់ដោយសារការប៉ះពាល់ទៅនឹងការបំពុលបរិស្ថាន និងឥទ្ធិពលផ្សេងៗពីអាកាសធាតុ។

## ការកសាងភាពជាដៃគូផ្សេងៗ

**វិធីសាស្ត្រទី 4៖** គិតត្រឹមខែធ្នូ ឆ្នាំ 2027 ត្រូវកាត់បន្ថយហានិភ័យនៃការពុលដោយសារជាតិសំណពីថ្នាំលាបដែលមានជាតិសំណនៅតាមផ្ទះចំនួន 2000 កន្លែងនៅទូទាំងខោនធី LA តាមរយៈការកែបំបាត់ចំណុចគ្រោះថ្នាក់ពីថ្នាំលាបដែលមានជាតិសំណ។

**វិធីសាស្ត្រទី 5៖** គិតត្រឹមខែធ្នូ ឆ្នាំ 2025 និងជារៀងរាល់ឆ្នាំបន្ទាប់ពីនេះ ត្រូវផ្តល់វគ្គបង្ហាត់ និងបង្កើតផែនការសម្រាប់ក្រុមផ្នែកសុខភាពដែលផ្តោតទៅលើសហគមន៍តូចៗដូចជាក្រុមផ្នែកសុខភាពសាធារណជននៅក្នុងសហគមន៍ (Community Public Health Teams/CPHTs) ដើម្បីបន្ថែមចំណេះដឹង និងការប្រុងប្រយ័ត្នចំពោះបញ្ហាទាក់ទងទៅនឹងបរិស្ថាន និងភាពយុត្តិធម៌ផ្នែកអាកាសធាតុនៅក្នុងតំបន់នៅតាមសហគមន៍សាកល្បងដំបូងៗ។

**វិធីសាស្ត្រទី 6៖** គិតត្រឹមខែមិថុនា ឆ្នាំ 2026 ត្រូវធ្វើជាដៃគូជាមួយនឹងអង្គការផ្នែកភាពយុត្តិធម៌ទាក់ទងទៅនឹងបរិស្ថាន និងផ្នែកសុខភាពទាក់ទងទៅនឹងអាកាសធាតុនៅក្នុងខោនធី LA ដើម្បីគាំទ្រ និងរៀបចំទីកន្លែងសម្រាប់សន្និសីទអ្នកជំនាញចំពោះប្រធានបទទាំងឡាយផ្នែកភាពយុត្តិធម៌ទាក់ទងទៅនឹងបរិស្ថាន និងផ្នែកសុខភាពទាក់ទងទៅនឹងអាកាសធាតុ។

# សកម្មភាពបែបសហការ

## 1. ចូលរួមចំណែកដល់ទិន្នន័យ និងការតាមដាន

ចែករំលែកទិន្នន័យ ដើម្បីយល់ដឹងអំពីបញ្ហាផ្សេងៗផ្នែកបរិស្ថានដែលមានឥទ្ធិពលក្នុងលក្ខណៈអវិជ្ជមានទៅលើសុខភាពរបស់សហគមន៍នានានៅក្នុងខោនធី LA និងប្រសិទ្ធិភាពនៃការធ្វើអន្តរាគមន៍ ដើម្បីធ្វើឱ្យសុខភាពប្រសើរឡើង។

## 2. ចូលរួមបង្កើត ដាក់អនុវត្ត ប្រតិបត្តិគោលការណ៍ដោយសកម្ម

ចូលរួមធ្វើកិច្ចការជាមួយនឹងអ្នកចូលរួមចំណែកដែលមានលក្ខណៈខុសៗគ្នាដោយរួមមានអ្នកបង្កើតគោលនយោបាយ ទីភ្នាក់ងារមានអំណាចធ្វើបទបញ្ញត្តិ អង្គការមិនរកប្រាក់ចំណេញ និងពលរដ្ឋទាំងឡាយ ដើម្បីធ្វើឱ្យភាពយុត្តិធម៌ផ្នែកបរិស្ថាន និងសុខភាពទាក់ទងទៅនឹងអាកាសធាតុឈានទៅរកការផ្លាស់ប្ដូរគោលនយោបាយដែលមានអត្ថន័យ។ កំណត់ និងផ្ដោតទៅលើសហគមន៍ផ្នែកភាពយុត្តិធម៌ទាក់ទងទៅនឹងបរិស្ថាននៅគ្រប់កម្រិតនៃការធ្វើកិច្ចការផ្នែកគោលនយោបាយ។ គាំទ្រមតិចំពោះគោលនយោបាយនានាដែលដោះស្រាយចំពោះបញ្ហាជួរមុខនៅក្នុងសហគមន៍ ដោយរួមមានការប៉ះពាល់ទៅនឹងការបំពុលបរិស្ថានដែលមានលក្ខណៈត្រួតលើគ្នា។ គាំទ្រមតិចំពោះគោលនយោបាយនានាដែលធ្វើឱ្យភាពមានសុខភាពល្អបានជឿនលឿន តាមរយៈការគាំពារប្រជាជនដែលងាយស្រួលនឹងរងគ្រោះពីការប៉ះពាល់ទៅនឹងសារធាតុបំពុលបរិស្ថានដែលនាំឱ្យមានសុខភាពខុសគ្នា និង/ឬកាត់បន្ថយការប៉ះពាល់ទៅនឹងសារធាតុបំពុលបរិស្ថានដែលនាំឱ្យមានសុខភាពខុសគ្នា។

## 3. ចូលរួមជាមួយនឹងចំណុចអទិភាព និងកម្មវិធីផ្សេងៗដែលមានការជំរុញដោយសហគមន៍

ផ្ដល់ជំនឿចិត្តដល់សហគមន៍ និងពលរដ្ឋទាំងឡាយតាមរយៈការចូលរួមធ្វើកិច្ចការជាមួយនឹងពួកគេដោយសកម្មក្នុងការរៀបចំផែនការ ការចាត់ចំណុចអទិភាព និងការដាក់អនុវត្តន៍វិធីសាស្ត្រផ្សេងៗ ក៏ដូចជាដំណើរការនៃការសម្រេចចិត្តដែលទាក់ទងទៅនឹងភាពយុត្តិធម៌ផ្នែកបរិស្ថាន និងសុខភាពទាក់ទងទៅនឹងអាកាសធាតុ។

## 4. កសាងលទ្ធភាពរបស់សហគមន៍ ដើម្បីដោះស្រាយចំពោះបញ្ហាផ្នែកបរិស្ថាននៅក្នុងតំបន់

អប់រំដល់សហគមន៍នានាដែលទទួលរងការប៉ះពាល់ក្នុងកម្រិតខុសគ្នាដោយមិនអាចប្រៀបធៀបបានអំពីឥទ្ធិពលត្រួតលើគ្នា ការប្រើប្រាស់ដី និងដំណើរការនៃការសម្រេចចិត្តក្នុងលក្ខណៈផ្សេងទៀតដែលធ្វើឱ្យមានការប៉ះពាល់ទៅនឹងប្រភពនៃការបំពុលបរិស្ថានជាច្រើនប្រភេទជាប់រហូតទៅនៅក្នុងសហគមន៍ផ្នែកភាពយុត្តិធម៌ទាក់ទងទៅនឹងបរិស្ថានទាំងឡាយ។

# ចំណុចត្រូវផ្តោតទៅលើទី 4៖ ការទប់ស្កាត់អំពើហិង្សា



## សេចក្តីថ្លែងការណ៍អំពីលទ្ធផល៖

ក្រុមគ្រួសារ និងសហគមន៍ទាំងអស់នៅក្នុងខោនធី Los Angeles រស់នៅដោយមិនមានអំពើហិង្សា ព្រមទាំងរីកចម្រើននៅក្នុងទម្លាប់មួយដែលប្រកបដោយសន្តិភាព។

## គោលដៅផ្សេងៗដែលអាចសម្រេចបាន៖

1. កាត់បន្ថយគម្លាតនៃអត្រាអំពើមនុស្សឃាតរវាងជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក និងចំនួនមធ្យមរបស់ខោនធី Los Angeles ឱ្យបានចំនួន 20% ក្នុងរយៈពេលប្រាំឆ្នាំ។

2. កាត់បន្ថយចំនួនស្ត្រីពេញវ័យ និងអ្នកដែលមានភេទផ្សេងទៀត/ភេទមិនដូចការគិតជាទូទៅដែលរាយការណ៍ថាធ្លាប់បានជួបប្រទះនៅនឹងអំពើហិង្សាផ្នែកផ្លូវកាយពីដៃគូស្នេហាឱ្យបានចំនួន 10% ក្នុងរយៈពេលប្រាំឆ្នាំ។

# វិធីសាស្ត្រផ្សេងៗ

## ទិន្នន័យដែលមានប្រយោជន៍ និងមានការគិតគូរដល់មនុស្សគ្រប់រូប

**វិធីសាស្ត្រទី 1៖** គិតត្រឹមខែមិថុនា ឆ្នាំ 2025 ត្រូវបង្កើតគេហទំព័រដើមមានផ្ទុកទិន្នន័យដែលមានលក្ខណៈប្រមូលផ្តុំ និងបើកចំហមួយដោយមានប្រព័ន្ធស្ទង់ ដើម្បីវាយតម្លៃទៅលើការឈានទៅមុខនៃគោលដៅ និងគោលបំណងផ្សេងៗនៅក្នុងផែនការតាមវិធីសាស្ត្រត្រឹមត្រូវរបស់ការិយាល័យផ្នែកការទប់ស្កាត់អំពើហិង្សា (OVP)។

## ការផ្លាស់ប្តូរគោលការណ៍ និងប្រព័ន្ធគ្រប់គ្រងផ្សេងៗ

**វិធីសាស្ត្រទី 2៖** គិតត្រឹមខែមករា ឆ្នាំ 2026 បង្កើតឱ្យមានគណៈកម្មាធិការផ្នែកការបំពានផ្លូវភេទ (Sexual Assault Council) ក្នុងការកែលម្អដល់ការសម្របសម្រួលរវាងប្រព័ន្ធគ្រប់គ្រងរបស់ខោនធី និងអ្នកផ្តល់សេវាកម្មទាំងឡាយ ដើម្បីកែលម្អសេវាកម្មផ្សេងៗសម្រាប់អ្នកធ្លាប់ទទួលរងការបំពានផ្លូវភេទ និងវិនិយោគទៅលើកម្មវិធីផ្សេងៗផ្នែកការទប់ស្កាត់។





## ការកសាងភាពជាដៃគូផ្សេងៗ

**វិធីសាស្ត្រទី 3៖** គិតត្រឹមតែកក្កដា ឆ្នាំ 2026 ត្រូវបន្ថែមគំនិតផ្តួចផ្តើម និងសេវាកម្មផ្សេងៗ ដើម្បីដោះស្រាយបញ្ហាផ្អែកអំពើហិង្សាដែលផ្អែកទៅលើភេទនៅពេញមួយជីវិតតាមរយៈការជួយពង្រឹងដល់ការសហការរវាងទីភ្នាក់ងារនានា។

**វិធីសាស្ត្រទី 4៖** គិតត្រឹមខែមិថុនា ឆ្នាំ 2027 ត្រូវបន្ថែមកិច្ចខំប្រឹងប្រែងផ្អែកសុវត្ថិភាពរបស់សាធារណជនដែលផ្អែកទៅលើទីកន្លែង និងមានការជំរុញដោយសហគមន៍តាមរយៈកម្មវិធីគំនិតផ្តួចផ្តើមចំពោះការទប់ស្កាត់មិនឱ្យមានការប៉ះទង្គិចផ្លូវចិត្ត (Trauma Prevention Initiative/TPI) ដោយរួមមានបណ្តាញចុះដោយផ្ទាល់ទៅតាមផ្លូវ (Street Outreach) និងការធ្វើអន្តរាគមន៍ចំពោះអំពើហិង្សានៅក្នុងសហគមន៍ (Community Violence Intervention/CVI) ការធ្វើអន្តរាគមន៍ចំពោះអំពើហិង្សានៅតាមមន្ទីរពេទ្យ (Hospital Violence Intervention/HVIP) ហើយនិងបណ្តាញសកម្មភាពក្នុងសហគមន៍សម្រាប់សន្តិភាព (Community Action for Peace) តាមរយៈ 1) ការបង្កើនការវិនិយោគទៅក្នុងសហគមន៍ចំនួនប្រាំបួន និង 2) ការកសាងប្រព័ន្ធដំណើរការក្នុងសង្គមសម្រាប់ការបង្ហាត់អំពីការធ្វើអន្តរាគមន៍ចំពោះអំពើហិង្សារវាងអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នា ហើយនិងការធ្វើឱ្យសេវាកម្មផ្សេងៗពីខោនធីមានការស្របទៅតាមគ្នា។

**វិធីសាស្ត្រទី 5៖** គិតត្រឹមខែមិថុនា ឆ្នាំ 2025 ត្រូវដាក់អនុវត្តផែនការដែលមានលក្ខណៈពេញលេញមួយ ដើម្បីគាំទ្រដល់ការប្រើប្រាស់កាំភ្លើងដោយសុវត្ថិភាព តាមរយៈការអប់រំ និងការធ្វើឱ្យសហគមន៍មានការប្រុងប្រយ័ត្ន ការផ្លាស់ប្តូរគោលការណ៍ ហើយនិងការទំនាក់ទំនងទៅកាន់អ្នកដែលមានអាយុប្រហាក់ប្រហែលគ្នា។

## ភាពត្រៀមខ្លួនជាស្រេច និងលទ្ធភាពផ្នែកការចាត់តាំង

**វិធីសាស្ត្រទី 6៖** គិតត្រឹមខែមិថុនា ឆ្នាំ 2026 ត្រូវដាក់អនុវត្តប្រព័ន្ធដំណើរការផ្សេងៗប្រកបដោយការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត និងហ្វឹកហាត់ធ្វើការផ្លាស់ប្តូរក្នុងចំណោមនាយកដ្ឋានទាំងឡាយរបស់ខោនធី ព្រមទាំងដៃគូនានានៅក្នុងសហគមន៍ ដើម្បីគាំទ្រដល់ការបានធូរស្បើយឡើងវិញ និងសុខុមាលភាព ហើយនិងគាំទ្រដល់តម្រូវការដែលមានលក្ខណៈពិសេសៗរបស់សហគមន៍នានានៅក្នុងតំបន់។

**វិធីសាស្ត្រទី 7៖** គិតត្រឹមខែមិថុនា ឆ្នាំ 2026 ត្រូវបង្កើតវិធីសាស្ត្រផ្នែកទំនាក់ទំនងដែលមានការសម្របសម្រួលត្រឹមត្រូវមួយ ដើម្បីគាំទ្រដល់ការយល់ដឹងរួមគ្នាអំពីអំពើហិង្សា និងអំពើហិង្សាក្នុងលក្ខណៈជាបញ្ហាផ្នែកសុខភាពសាធារណជន។

**វិធីសាស្ត្រទី 8៖** គិតត្រឹមខែមិថុនា ឆ្នាំ 2025 ត្រូវដាក់អនុវត្តកិច្ចខំប្រឹងប្រែងផ្សេងៗនៅក្នុងតំបន់ ដើម្បីទប់ស្កាត់ការធ្វើអត្តឃាត និងទង្វើបែបចង់ធ្វើអត្តឃាតក្នុងចំណោមប្រជាជនដែលបង្ហាញចេញមកថាប្រឈមនឹងហានិភ័យខ្ពស់ ដោយរួមមានយុវវ័យមនុស្សនៅក្នុងសហគមន៍អ្នកដែលមិនមែនជាជនជាតិស្បែកស អតីតយុទ្ធជន និងម្ចាស់កាំភ្លើងទាំងឡាយ។

# សកម្មភាពបែបសហការ

## 1. ចូលរួមចំណែកដល់ការស្រាវជ្រាវ និងទិន្នន័យដែលមានការគិតគូរដល់មនុស្សគ្រប់រូប

- កំណត់ និងចែករំលែកទិន្នន័យ ដើម្បីដោះស្រាយចំពោះបញ្ហាចន្លោះប្រហោងនៅក្នុងទិន្នន័យ និងធ្វើឱ្យយល់បានកាន់តែច្បាស់លាស់អំពីទ្រង់ទ្រាយខុសៗគ្នានៃអំពើហិង្សា ដោយរួមមានអំពើហិង្សាដោយប្រើប្រាស់កាំភ្លើង ការធ្វើអត្តឃាត អំពើហិង្សាដែលមានការស្អប់ខ្ពើម អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាផ្នែកផ្លូវភេទ និងការជួញដូរមនុស្ស។
- គាំទ្រដល់កិច្ចខំប្រឹងប្រែងក្នុងការប្រមូលយកទិន្នន័យដែលមានគុណភាពដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់លាស់អំពីកាលៈទេសៈនៃអំពើហិង្សា និងឥទ្ធិពលនៃគំរូអនុវត្តន៍ប្រកបដោយការយល់ដឹងអំពីការធូរស្បើយឡើងវិញ និងមានការផ្តោតទៅលើសហគមន៍ ដូចជាការទំនាក់ទំនងទៅកាន់អ្នកដែលមានអាយុប្រហាក់ប្រហែលគ្នា និងការនិយាយសាច់រឿងប្រាប់ ដើម្បីធ្វើឱ្យពាក្យសម្តីរបស់បុគ្គលទាំងឡាយដែលបានទទួលរងការប៉ះពាល់ដោយអំពើហិង្សានោះមានលក្ខណៈខ្លាំងឡើង ហើយនិងការគាំទ្រដល់ការស្រាវជ្រាវនៅតាមសហគមន៍បែបមានការចូលរួម។

## 2. គាំទ្រមតិចំពោះការផ្លាស់ប្តូរគោលការណ៍ និងប្រព័ន្ធគ្រប់គ្រងផ្សេងៗ

- គាំទ្រ និងដាក់អនុវត្តគោលការណ៍ និងគំរូអនុវត្តន៍ផ្សេងៗដែលធ្វើឱ្យមធ្យោបាយប្រកបដោយការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត និងគំរូអនុវត្តន៍ផ្នែកការធូរស្បើយឡើងវិញបានជឿនលឿន ហើយនិងគោលការណ៍ និងគំរូអនុវត្តន៍នានាដែលកាត់បន្ថយកត្តាផ្សេងៗនៃការរើសអើងជាតិសាសន៍ និងភាពលម្អៀង។ លើសពីនេះទៀត ត្រូវគាំទ្រដល់ដំណើរការផ្សេងៗដែលអ្នកធ្លាប់ទទួលរងផលប៉ះពាល់ និងសមាជិកសហគមន៍ ដោយរួមមានទាំងយុវវ័យផងដែរនោះ អាចផ្តល់ព័ត៌មាន និងចូលរួមក្នុងការបង្កើតគោលការណ៍ និងគំរូអនុវត្តន៍ទាំងនេះបាន។
- គាំទ្រ និងដាក់អនុវត្តគោលការណ៍ និងគំរូអនុវត្តន៍ផ្សេងៗដែលធ្វើឱ្យអង្គការមូលដ្ឋាននៅតាមសហគមន៍អាចទទួលបានការផ្តល់ទឹកប្រាក់កាន់តែងាយស្រួល ដើម្បីជួយធ្វើឱ្យភាពសមធម៌បានជឿនលឿន ដោយរួមមានការធ្វើជាដៃគូជាមួយនឹងទីភ្នាក់ងារផ្នែកប្រាក់កាស ការធ្វើឱ្យតម្រូវការចាំបាច់ទាក់ទងទៅនឹងកិច្ចសន្យាមានលក្ខណៈកាន់តែមានប្រសិទ្ធិភាពនិងសាមញ្ញ ការពិនិត្យទៅលើតម្រូវការចាំបាច់ផ្សេងៗរបស់ខោនធីផ្នែកធានារ៉ាប់រង បន្ថែមពីលើការផ្តល់ទឹកប្រាក់ដល់គំនិតផ្តួចផ្តើមទាក់ទងទៅនឹងជំនួយផ្នែកបច្ចេកទេសដែលកសាងលទ្ធភាពរបស់អង្គការមូលដ្ឋានទាំងឡាយ។

# សកម្មភាពបែបសហការ

### 3. ចូលរួម និងគាំទ្រកម្មវិធី និងចំណុចអទិភាពផ្សេងៗដែលមានការជំរុញដោយសហគមន៍

- គាំទ្រដល់ការបង្កើតកម្មវិធីផ្សេងៗ ដូចជាមជ្ឈមណ្ឌលសម្រាប់យុវវ័យដែលមានភាពសន្តនិយម និងមានការពាក់ព័ន្ធផ្នែកវប្បធម៌ ហើយដែលមានផ្តល់ធនធាននិងសេវាកម្មផ្សេងៗ កសាងភាពជាអ្នកដឹកនាំចំពោះយុវវ័យ ហើយនិងធ្វើឱ្យផ្នែកសិល្បៈ ការជួរស្បើយឡើងវិញ និងការកែតម្រូវការខូចខាតផ្សេងៗដែលបង្កឡើងដោយបទល្មើសប្បជម្លោះបានជឿនលឿន ព្រមទាំងគាំទ្រដល់គំនិតផ្តួចផ្តើមមានស្រាប់នៅតាមសហគមន៍ និងប្រកបដោយការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត។
- ចូលរួមជាមួយនឹងអង្គការ និងដៃគូផ្សេងៗនៅតាមសហគមន៍នៅក្នុងក្រុមចម្រុះផ្នែកការទប់ស្កាត់អំពើហិង្សាក្នុងតំបន់ និងបណ្តាញផ្នែកសកម្មភាពក្នុងសហគមន៍សម្រាប់សន្តិភាព ដើម្បីគាំទ្រដល់ភាពជាដៃគូ និងការសហការនៅក្នុងតំបន់។ បង្កើតការយល់ដឹងរួមគ្នាអំពីមូលហេតុដើមនៃអំពើហិង្សា មធ្យោបាយបែបសុខភាពសាធារណជន ការប៉ះទង្គិចផ្លូវចិត្តនិងការជួរស្បើយឡើងវិញ ការរើសអើងជាតិសាសន៍ និងការគាបសង្កត់ដែលមាននៅក្នុងប្រវត្តិសាស្ត្រជាផ្នែកនៃផែនការសម្រាប់ការទប់ស្កាត់នៅក្នុងតំបន់។
- ធ្វើឱ្យគំនិតផ្តួចផ្តើមផ្សេងៗដែលគាំទ្រដល់សុខភាព ការជួរស្បើយឡើងវិញ និងសុខុមាលភាពនៅក្នុងសហគមន៍នានាដែលទទួលរងការប៉ះពាល់ដោយអំពើហិង្សាបានស្របនឹងគ្នា ដូចជាសហគមន៍ដែលមានកម្មវិធីគំនិតផ្តួចផ្តើមចំពោះការទប់ស្កាត់មិនឱ្យមានការប៉ះទង្គិចផ្លូវចិត្ត ដើម្បីកសាងមធ្យោបាយមួយមានភាពសន្តនិយម ហើយនៅក្នុងទីកន្លែងដែលរៀបចំជាពិសេសសម្រាប់តម្រូវការ និងធនធានរបស់សហគមន៍នីមួយៗ។ កំណត់ប្រភេទធនធាន និងភាពជាដៃគូបន្ថែមទៀត ដើម្បីចែករំលែកសោសុវត្ថិភាពសម្រាប់ចាក់កាំភ្លើងទុកដោយមិនគិតថ្លៃនៅទូទាំងខោនធី។

### 4. វិនិយោគទៅលើគំនិតផ្តួចផ្តើមផ្សេងៗផ្នែកការកែប្រែការចាត់តាំង

- វិនិយោគទៅលើការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងផ្សេងៗប្រកបដោយការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត ដោយរួមមានវគ្គបង្ហាត់សម្រាប់កម្លាំងការងារនៅគ្រប់កម្រិត ការហ្វឹកហាត់សម្រាប់យុវវ័យនិងអង្គការនានាដែលធ្វើកិច្ចការជាមួយនឹងយុវវ័យ ហើយនិងការធ្វើឱ្យគំរូអនុវត្តន៍និងគោលការណ៍ផ្សេងៗផ្នែកការចាត់តាំងស្របទៅតាមគ្នាក្នុងលក្ខណៈដែលគាំទ្រដល់បុគ្គលិក ផ្តល់ធនធានផ្សេងៗ និងដោះស្រាយចំពោះបញ្ហាការប៉ះទង្គិចផ្លូវចិត្តរបស់អ្នកដទៃដែលជះឥទ្ធិពលមកលើខ្លួន ព្រមទាំងបញ្ហាលែងសូវមានភាពអាណិតអាសូរ។
- វិនិយោគទៅលើកម្មវិធី និងគំនិតផ្តួចផ្តើមផ្សេងៗតាមរយៈការផ្តល់ធនធានផ្សេងៗ និងការផ្តល់ទឹកប្រាក់ដែលមានលក្ខណៈបត់បែនបានដែលជួយឱ្យមានការឆ្លើយតបបែបលឿន លើកទឹកចិត្តឱ្យមានវិធីសាស្ត្រថ្មីៗនិងប្រកបដោយភាពច្នៃប្រឌិត ហើយនិងសមត្ថភាពក្នុងការសម្របសម្រួលទៅតាមកាលៈទេសៈថ្មីៗបំផុតនៅក្នុងសង្គម ក៏ដូចជាបរិស្ថានផ្នែកនយោបាយ និងផ្នែកផ្លូវកាយ។
- ផ្តល់ធនធានផ្សេងៗ និងមានការផ្តល់ទឹកប្រាក់ជាបន្តបន្ទាប់ទុកសម្រាប់ការទ្រទ្រង់ និងបន្ថែមទៅលើកម្មវិធីផ្សេងៗ ដូចជាកម្មវិធី Parks After Dark កម្មវិធី Summer Night Lights កម្មវិធី Crisis Response កម្មវិធី Street Outreach និង Hospital Violence Intervention Programs (HVIPs) នៅតាមមណ្ឌលព្យាបាលរបួសកម្រិតខ្លាំងក្នុងសហគមន៍នានាដែលមានអំពើហិង្សាក្នុងកម្រិតខ្ពស់។
- វិនិយោគទៅលើយុទ្ធនាការផ្នែកការទំនាក់ទំនងដែលមានការសម្របសម្រួលត្រឹមត្រូវ ដើម្បីគាំទ្រដល់ចំណុចដែលថាអំពើហិង្សាគឺជាបញ្ហាផ្នែកសុខភាពសាធារណជនដែលអាចទប់ស្កាត់បាន ហើយនិងបង្កើតរបៀបផ្ញើសារដែលអាចប្រើប្រាស់បានជាទូទៅ និងក្នុងលក្ខណៈថ្មី ដើម្បីចូលរួមជាមួយនឹងអ្នករួមចំណែកខុសៗគ្នាដែលទទួលរងការប៉ះពាល់ដោយអំពើហិង្សា។

ការផ្លាស់ប្តូរតម្រូវចាំបាច់ឱ្យនាយកដ្ឋានសុខភាពសាធារណៈ និងដៃគូទាំងឡាយមានឆន្ទៈ និងការប្តេជ្ញាចិត្តជារួម។

លទ្ធផលផ្សេងៗនៅក្នុងផែនការនេះគឺមិនអាចសម្រេចបានឡើយតាមរយៈការធ្វើកិច្ចការនានាដោយរៀងៗខ្លួននោះ។

យើងខ្ញុំសង្ឃឹមថាផែនការនេះផ្តល់នូវការពន្យល់ដោយលម្អិតមួយដែលអាចប្រើប្រាស់ជារួមសម្រាប់ការកាត់បន្ថយការមិនមានភាពសមធម៌ផ្នែកសុខភាព តាមរយៈការដោះស្រាយមូលហេតុដើមទាំងឡាយនៃកម្រិតខុសគ្នាដោយមិនអាចប្រៀបធៀបបាននៃលទ្ធផលផ្នែកសុខភាពផ្សេងៗ។

ពិនិត្យមើលរបៀបធ្វើជាដៃគូជាមួយនឹងយើងខ្ញុំនៅលើគេហទំព័រ៖

http://publichealth.lacounty.gov/pie/planning/chip.htm

